# ការណែនាំអំពីប្រព័ន្ធសិទ្ធិនិងគាំពារជនបរទេសដែលរងគ្រោះដោយសារឧក្រិដ្ឋកម្ម

ប្រសិនបើអ្នកត្រូវរងគ្រោះដោយបទឧក្រិដ្ឋ អ្នកអាចទទួលបានសិទ្ធិនិងជំនួយក្នុងអំឡុងពេលធ្វើការស៊ើបអង្កេត ឬ ការកាត់ក្តីដូចខាងក្រោម។

- ក្នុងអំឡុងពេលនៃការស៊ើបអង្កេត ឬ ការកាត់ក្តី ប្រសិនបើអ្នកមានអារម្មណ៍ថា មានការព្រួយបារម្ភភ័យខ្លាច ឬភាពតានតឹងអ្នកអាចរកនរណាម្នាក់ដែលមានជំនឿទុកចិត្ត, ដើម្បីស្នើសុំអ្នកបកប្រែសម្រាប់ទំនាក់ទំនង, អ្នកអាចចូលរួមក្នុងការជំនុំជម្រះដើម្បីបញ្ជាក់ពីគំនិតរបស់អ្នកលើករណីនេះ។

- ប្រសិនបើអ្នកជាជនរងគ្រោះនៃអំពើហឹង្សាផ្លូវភេទ ឬ បទល្មើសរំលោភបំពានលើកុមារ អ្នកអាចមានសិទ្ធិជ្រើសរើសមេធាវីដើម្បីទទួលបានជំនួយផ្នែកច្បាប់ក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រសិនបើអ្នកមិនមានមេធាវីអ្នកអាចទទួលបានជំនួយពីមេធាវីដែលត្រូវបានជ្រើសរើសដោយព្រះរាជអាជ្ញា។

- ប្រសិនបើអ្នកជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ ឬ បទល្មើសរំលោភបំពានលើកុមារ អ្នកអាចស្នើសុំឱ្យព្រះរាជអាជ្ញា ឬ ប៉ូលីស ចាត់វិធានការដូចជាការប្រឆាំងនឹងជនល្មើស ឬ អ្នកអាចស្នើសុំតុលាការ ចាត់វិធានការដើម្បីការពារអ្នកដោយផ្ទាល់។

- ប្រសិនបើអ្នកមិនបានទទួលសំណងពីជនល្មើស អ្នកអាចទទួលបានការជួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ ឬ ថ្លៃព្យាបាល។ល។ ពីការិយាល័យព្រះរាជអាជ្ញា។ (ទោះជាយ៉ាងណា, នៅក្នុងករណីនេះ ជនរងគ្រោះត្រូវមានស្ថានភាពរស់នៅស្របច្បាប់នៅក្នុងប្រទេសកូរ៉េ ហើយប្រសិនបើជនល្មើសជាជនបរទេសនោះ ជនរងគ្រោះត្រូវតែបំពេញការចុះបញ្ជីជនបរទេសសូមបន្តសិទ្ធិស្នាក់នៅ។)

- ប្រសិនបើអ្នកជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ ឬ ការរំលោភផ្លូវភេទ អ្នកអាចស្នើសុំការអនុញ្ញាតឱ្យពន្យារការស្នាក់នៅរហូតដល់ការស៊ើបអង្កេត ការកាត់ក្តី ឬ សំណងត្រូវបានបញ្ចប់។(ទោះយ៉ាងណាក៏ដោយ ក្នុងករណីមានអំពើហិង្សាក្នុងគ្រួសារនេះស្វាមីភរិយាត្រូវតែជាជនជាតិកូរ៉េ។)

- ក្នុងករណីជួយសង្គ្រោះជនរងគ្រោះនៃឧក្រិដ្ឋកម្ម ដូចជាឃាតកម្ម, គ្រោះថ្នាក់ខាងរាងកាយ, របួសជាដើម។ ឬបទល្មើសព្រហ្មទណ្ឌដូចជាការខូចខាត ទ្រព្យសម្បត្តិ ក្លែងបន្លំ និងឧក្រិដ្ឋកម្មផ្លូវភេទ, ទោះបីជាជនរងគ្រោះគឺជាជនបរទេសដែលខុសច្បាប់ក៏ដោយ ក៏មន្ត្រីនោះអាចឬនឹងមិនអាចជូនដំណឹងទៅការិយាល័យអន្តោប្រវេសន៍នូវអត្តសញ្ញាណរបស់គាត់បានដែរ។

※ សម្រាប់ព័ត៌មានបន្ថែមសូមទូរស័ព្ទទៅការិយាល័យគាំពារជនរងគ្រោះនៃការិយាល័យព្រះរាជអាជ្ញា (☎1577-2584) ឬសូមចូលទៅកាន់វេបផូថលយុត្តិធម៌ព្រហ្មទណ្ឌ ដើម្បីត្រួតពិនិត្យ។

※ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែ ដើម្បីទូរស័ព្ទទៅការិយាល័យព្រះរាជអាជ្ញា ឬ ទៅការិយាល័យរបស់ព្រះរាជអាជ្ញាដើម្បីពិគ្រោះយោបល់, សូមទាក់ទងទៅស្ថានទូត ប្រចាំប្រទេសរបស់ខ្លួន ឬ មជ្ឈមណ្ឌលគាំពារគ្រួសារពហុវប្បធម៌ (☎1577-1366) សាកសួរថាតើ អាចផ្តល់សេវាបកប្រែភាសាជូនទៅការិយាល័យព្រះរាជអាជ្ញាបានដែលឬទេ។

<បញ្ជាក់ថាអ្នកបានទទួលព័ត៌មានខាងលើ។> 20 . . . បញ្ជាក់ឈ្មោះ (ហត្ថលេខា)

<អាចទាក់ទងដោយវិធីសាស្ត្រផ្សេងៗ> និយាយ□ ទូរស័ព្ទ□ ទូរសារ□ សំបុត្រ□ ផ្សេងៗ□ អ្នកទទួលខុសត្រូវ (ហត្ថលេខា)